# អនុក្រឹត្យលេខ ៤៥ អនក្រ.បក

## ស្តីពី

## ការបង្កើតក្រុមការងារជាន់ខ្ពស់

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៨០០/១៥២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍវិស័យបច្ចេកវិទ្យា គមនាគមណ៍ ពត៌មានវិទ្យា

យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១.-** បង្កើតក្រុមការងារជាន់ខ្ពស់មួយ ដើម្បីសំរបសំរួលការងារគំរោង បច្ចេកវិទ្យា គមនាគមណ៍ ពត៌មានវិទ្យា ក្នុងក្របខ័ណ្ឌជំនួយមូលនិធិសហប្រតិបត្តិការអភិវឌ្ឍណ៍សេដ្ឋកិច្ចពីសាធារណរដ្ឋកូរ៉េ ជាមួយអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍណ៍បច្ចេកវិទ្យា គមនាគមណ៍ ពត៌មាន វិទ្យា និងបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន

២-ឯកឧត្តម **ឡា ណារ៉ាត** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាសមាជិក

៣-ឯកឧត្តម **ត្រាក់ ថៃសៀង** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរងទី១ រាជធានីភ្នំពេញ ជាសមាជិក

៤-លោក **អ៊ុង ជុនឈួរ** អគ្គនាយករងក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

៥-លោក **មាន្យ ទិបុលចន្ទ្រា** អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខក្រសួងមហាផ្ទៃ ជាសមាជិក

៦-លោក **ឡោ ជាវុធ** ប្រធាននាយកដ្ឋានបច្ចេកទេស នៃអគ្គនាយកដ្ឋាន ស៊ុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិក

**ប្រការ ២.-** ក្រុមការងារនេះដំណើរការ ការងារក្រោមការដឹកនាំរបស់ប្រធាន រឺ សមាជិកណាម្នាក់ដែលប្រធានប្រគល់សិទ្ធិឱ្យ ។

**មាត្រា ៣.-** ក្នុងករណីចាំបាច់ ប្រធានក្រុមការងារបច្ចេកទេសជាន់ខ្ពស់ អាចលើកសំណើបំពេញបន្ថែមសមាជិករបស់ខ្លួនតាមតំរូវការជាក់ស្តែង។

**មាត្រា ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តមអគ្គលេខាធិការ អាជ្ញាធរជាតិទទួលបន្ទុកការងារអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា ឯកឧត្តម អស់លោកតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

**អនុក្រឹត្យលេខ ៤៦ អនក្រ.បក**

**ស្តីពីការផ្ទេរឥណទានថវិកា**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា